ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២២៧

ចុះថ្ងៃ ទី២១ខែសីហាឆ្នាំ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ

សាលដីការបៀប

តុលាការកំពូល

លេខ : ១២៧

ចុះថ្ងៃទី២៣ខែកក្កដាឆ្នាំ២០០២

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៣ ខែកក្កដា-ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ:-

១-ឯកឧត្តម ឌិត មុន្នី ជាប្រធាន

២-លោក វៀល មូន ជាចៅក្រម

៣-លោក ជីវ កេង ជាចៅក្រម

៤-លោក ស៊ុន ឌឹម ជាចៅក្រម

៥-លោក ព្រាក់ គឹមសាន ជាចៅក្រម

៦-លោក ឃឹម ស៊ីផល ជាចៅក្រម

៧-លោក សោម សិរីវុឌ្ឍ ជាចៅក្រម

៨-លោក យស់ សូខឿន ជាចៅក្រមរបាយការណ៍

៩-លោក ប៉ែន សាវឿន ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី ឃុត សុគន្ធា

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញាស្តីទី

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីកាលេខ ២៧២ ចុះថ្ងៃទី ០២-៦-៩៨ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ២៧ ចុះថ្ងៃទី ១៩-៨-៩៧ របស់ សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ យុត វ៉ាន់ធឿន "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ របររកស៊ីជាងជួសជុលម៉ូតូ ទីលំនៅភូមិស្លងលិច ឃុំស្លង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

មេធាវី : លោក ឡោ ជុនធី

និងចុងចម្លើយឈ្មោះ ហុង សុខខេង "ដើមបណ្តឹងសាទុក្ខ" ភេទស្រី អាយុ ២៧ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅភូមិស្លងលិច ឃុំស្លង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

កម្មវត្ថុបណ្តឹង :ប្តឹងទាមទារដី

តាមបណ្តឹងសាទុក្ខលើកទី២លេខ ២៣៨ ចុះថ្ងៃទី២២_៦_៨៨ របស់ឈ្មោះ ហុង សុខខេង ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ២៧២ ចុះថ្ងៃទី ០២_៦_៨៨ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២:២៧ ចុះថ្ងៃទី ២១_៨_៨៨ របស់តុលាការ_កំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១០_១០_៨២ របស់ដើមចោទឈ្មោះ យុត វ៉ាន់ឌឿន ថាខ្លួនប្តឹងសុំសិទ្ធិលើកម្មសិទ្ធិដីសង់លំនៅដ្ឋានដែលខ្លួនបានទិញពីឈ្មោះ ហេង ហុង ជាឳពុករបស់ឈ្មោះ ហុង សុខខេង មានទំហំ ១៥ម គុណ ៥០ម ។ ក្រោយមកខ្លួនទិញពីគណៈកម្មាធិការឃុំស្លូង ទំហំ ៣ម គុណ ៥០ម ថែមទៀត ដល់ឆ្នាំ ១៩៨២ ខ្លួនបានធ្វើរបងព័ទ្ធជុំវិញដីនេះ ស្រាប់តែឈ្មោះ ហុង សុខខេង មកជំទាស់មិនអោយធ្វើថា ដី៣ម គុណ ៥០ម នេះជាដីរបស់គាត់ទៅវិញ ។

តាមពាក្យបណ្តឹងសារត្រទប់ចុះថ្ងៃទី ១២_៦_៨៣ របស់នាង ហុង សុខខេង ថាឈ្មោះ យុត វ៉ាន់ឌឿន បានធ្វើរបងចូលមកដីរបស់ខ្លួន ៣ម ។ ចំពោះដីដែលឳពុកខ្លួនបានលក់អោយមានទំហំ ១៥ម គុណ ៥០ម នោះខ្លួនទទួលស្គាល់ មានធ្វើលិខិតត្រឹមត្រូវ ប៉ុន្តែនៅពេលធ្វើរបងឈ្មោះនេះបានធ្វើបំពានលើដីរបស់ខ្លួន ៣មទៀត ទើបខ្លួនជំទាស់មិនអោយធ្វើ ។

បានឃើញសាលក្រមលេខ ១២៥ ចុះថ្ងៃទី ២០_៧_៨៥ របស់ តុលាការខេត្តកំពង់ចាម ដែលសំរេចដូចតទៅ :_

១_ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១០_១០_៨២ របស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២_ទទួលពាក្យបណ្តឹងសារត្រទប់ចុះថ្ងៃទី ១២_៦_៨៣ របស់ចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៣_ប្រគល់ដីកើតហេតុទំហំ ៣ម គុណ ៥០ម ស្ថិតនៅភូមិស្លូង ឃុំស្លូង ស្រុកត្បូងឃ្មុំ ខេត្ត_កំពង់ចាម អោយទៅឈ្មោះ យុត វ៉ាន់ឌឿន គ្រប់គ្រងជាកម្មសិទ្ធិ ។ តាមមតិណែនាំលេខ ០៣ ស ណ ន ចុះថ្ងៃទី ០៣_៦_៨៤ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ។

៤_រឹបអូសប្រាក់ប្រដាប់ក្តី គឺ ពន្ធហ៊ឹង និង ពន្ធចុះបញ្ជីក្តី ១.៨០០៛០០ ប្រាក់រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛០០ ប្រាក់អង្កេតស៊ើបសួរ ៥.០០០៛០០ សរុប ៧.០០០៛០០ ដែលដើមចោទបានបង់រួចហើយ ។ នៅពេលសាលក្រមចូលជាស្ថាពរបង្គាប់អោយចុងចម្លើយបង់សងទៅដើមចោទវិញ និង បង្គាប់អោយចុងចម្លើយបង់ពន្ធសមាមាត្រចំនួន ១ភាគរយនៃតម្លៃដីបន្ថែមទៀត គឺ $\frac{\text{១ គុណ ១.០០០.០០០}}{\text{១០០}}$ = ១០.០០០៛០០ ក្នុងនោះត្រូវដាក់ចូលថវិការដ្ឋ ៨០ភាគរយ_ គឺ $\frac{\text{៨០ គុណ ១០.០០០}}{\text{១០០}}$ =៨.០០០៛០០ និងត្រូវបានសំរាប់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន _

២០ គុណ $\frac{១០.០០០}{១០០}$ = ២.០០០រ.០០ ។ នៅពេលសាលក្រមចូលជាស្ថាពរត្រូវអោយដើម_ចោទបង់ទុកជាមុន ទើបបង្គាប់អោយចុងចម្លើយបង់សងជាក្រោយ ។

៥_សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ និង ចុងចម្លើយ បើភាគីណាមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

សាលក្រនេះត្រូវបាន ឈ្មោះ ហុង សុខខេង ប្តឹងឧទ្ធរណ៍ តាមបណ្តឹងចុះថ្ងៃទី ២៧_០៧_៨៥ លើសាលក្រមទាំងមូល ។

បាន ឃើញសាលដីកាលេខ ១៩១ ចុះថ្ងៃទី ២១_៥_៨៦ របស់ សាលាឧទ្ធរណ៍ ដែលសំរេចដូចតទៅ :-

១_ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ហុង សុខខេង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២_សំរេចបដិសេធសាលក្រមតុលាការខេត្តកំពង់ចាមលេខ ១២៥ ចុះថ្ងៃទី២០_៧_៨៥ ចោលអសារបង់ ។

៣_សំរេចថា ដីទំនាស់រក្សាទុកអោយនាង ហុង សុខខេង កាន់កាប់គ្រប់គ្រង ជាកម្មសិទ្ធិតទៅ តែផ្នែងខាងក្រោយដែលឈ្មោះ យុត វ៉ាន់ឌឿន សង់ផ្ទះឈយចូលហើយនោះ ទុកអោយ យុត វ៉ាន់ឌឿន ថែរក្សាតទៅ ។

៤_សំរេចរឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រ.០០ ដែលដើម_បណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង ២.៥៥០រ.០០ រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់ ៤៥០រ.០០ ចំណាយក្នុងកិច្ចប្រគល់ដីការគោះ ៥.០០០រ.០០ និង ចំណាយលើអាជ្ញា_ធរតុលាការ ៥.០០០រ.០០ សរុប ១៣.០០០រ.០០ ។

កាលបើបួលបណ្តឹងឧទ្ធរណ៍ បង្គាប់អោយឈ្មោះ យុត វ៉ាន់ឌឿន សងប្រាក់ចូបដាប់_ក្តីចំនួន ១៣.០០០រ.០០ ទៅអោយឈ្មោះ ហុង សុខខេង វិញ ។

៥_សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើក ផ្លូវប្តឹងសាទុក្ខរយៈពេលពីរខែ គិតពីថ្ងៃនេះតទៅ ។

សាលដីកានេះត្រូវបាន ឈ្មោះ យុត វ៉ាន់ឌឿន ប្តឹងសាទុក្ខតាមបណ្តឹងលេខ ១៣០_ ចុះថ្ងៃទី ៣១_៥_៨៦ លើសេចក្តីសំរេចទាំងមូល ។

បាន ឃើញសាលដីកាលេខ ១០៨ ចុះថ្ងៃទី ២៧_៦_៨៧ ដែលមានសេចក្តីសំរេច_ដូចតទៅ :-

១_ទទួលបណ្តឹងសាទុក្ខលេខ ១៣០ ចុះថ្ងៃទី ៣១_៥_៨៦ របស់លោក យុត វ៉ាន់ឌឿន ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២_ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១៩១ ចុះថ្ងៃទី ២១_៥_៨៦ របស់ សាលាឧទ្ធរណ៍ទាំងមូល ។

៣_បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៩០ ចុះថ្ងៃទី ៣០_៨_៩៦ របស់តុលាការ_កំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ។

៤_រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛០០ ដែលលោក យុត វ៉ាន់ឡឿន បានបង់រួចហើយនៅ តុលាការកំពូល គឺ :_

_ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛០០ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

_ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ហើយតម្រូវអោយអ្នកស្រី ហុង សុខខេង សងប្រាក់ចំនួន ១៩.០០០៛០០ នេះទៅលោក _ យុត វ៉ាន់ឡឿន វិញ ។

៥_សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៧_ខែ មិថុនា ឆ្នាំ ១៩៩៧ ។

សំណុំរឿងនេះតុលាការកំពូល បានបង្វិលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ។

បានឃើញសាលដីកាលេខ ២៧២ ចុះថ្ងៃទី ០២_៦_៩៨ របស់សាលាឧទ្ធរណ៍ ដែលសំរេចដូចតទៅ :_

១_ទទួលជំនុំជំរះរឿងក្តីនេះឡើងវិញ តាមអំណាចសាលដីកាលេខ ១០៨_ចុះថ្ងៃទី ២៧_៦_៩៧ របស់ តុលាការកំពូល ។

២_តម្កល់សាលក្រមលេខ ១៦៥ ចុះថ្ងៃទី ២០_៧_៩៤ របស់ តុលាការខេត្តកំពង់_ចាម ទុកជាបានការពេញទាំងមូល ។

៣_រឹបអូសប្រាក់ប្រដាប់ក្តីដាក់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛០០ ដែលដើមបណ្តឹង_ឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ២.៥៥០៛០០ រង្វាន់ក្រឡាបញ្ជីកាន់_ហិបប្រាក់ចំនួន ៤៥០៛០០ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥.០០០៛០០ និង ចំណាយលើអាជ្ញា_ធរ តុលាការចំនួន៥.០០០៛០០ ។

៤_សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើក ផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ ២៣៨ ចុះថ្ងៃទី ២២_៦_៩៨ របស់ឈ្មោះ_ហុង សុខខេង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណារបស់ឈ្មោះ ហុង សុខខេង ចុះថ្ងៃទី ១៤_៩_៩៨.

បានឃើញសារណាតបរបស់ឈ្មោះ យុត វ៉ាន់ឡឿន ចុះថ្ងៃទី ២៩_៩_៩៨.

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :_ សាលដីការដ្ឋប្បវេណី

លេខ ២៧២ ចុះថ្ងៃទី ០២_៦_៩៨ របស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

ក្រោយបានអានសារណារបស់ឈ្មោះ ហុង សុខខេង

បានស្តាប់ចម្លើយរបស់ឈ្មោះ យុត វ៉ាន់ធឿន ដែលបានឆ្លើយនាពេលសវនាការថា :_ ខ្លួនសង់ផ្ទះជាប់នឹងព្រំដីរបស់គាត់ ពេលនោះឈ្មោះ ហុង សុខខេង មិននៅទីនោះទេ ដីនេះខ្លួនទិញពីឪពុកគាត់ទំហំ ១៥ម គុណ ៥០ម នៅពេលធ្វើរបងខែ ៦_៩២ ក៏ចាប់ផ្តើមមានទំនាស់ ដោយឈ្មោះនេះបានដករបងរបស់ខ្លួនចោល ។ ដី៣ម នោះគឺខ្លួនបានទិញពីឃុំ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ទេព្យា ជុនធី មេធាវីការពារអោយដើមចោទ នាពេលសវនាការនេះថា :_ចំណុចកើតហេតុគឺនៅចន្លោះផ្ទះលោក យុត វ៉ាន់ធឿន និង ហុង សុខខេង ។

_លោក យុត វ៉ាន់ធឿន បានទិញដីពីលោក ហុង ហេង ទំហំ ១៥ម គុណ ៥០ម ដោយមានព្រំដីច្បាស់លាស់ គឺគ្មានទំនាស់ទេ ។

_ទំនាស់កើតឡើងនៅពេលដែល យុត វ៉ាន់ធឿន ធ្វើរបង ហើយត្រូវឈ្មោះ_ ហុង សុខខេង ដករបងចោល ។

_បញ្ហាដី ៣ម គុណ ៥០ម គឺកូនក្តីខ្លួនបានទិញពីឃុំ

_ហុង សុខខេង បានរំលោភយកដី ៣ម គុណ ៥០ម ក្នុងដី ១៥ម គុណ ៥០ម ដែល យុត វ៉ាន់ធឿន បានទិញពីឪពុកគាត់ ។

ខ្លួនសូមសំណូមពរ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់អ្នកស្រី ហុង សុខខេង ចម្លើយរបស់លោក យុត វ៉ាន់ធឿន និង សេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ .

## តុ លា ការ កំ ពូ ល

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ ២៣៨ ចុះថ្ងៃទី ២២_៦_៩៨ របស់ឈ្មោះ ហុង សុខខេង ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មក_ជំនុំជំរះដល់អង្គសេចក្តីបាន តាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២២៦ នៃ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា ដោយរឿងក្តីនេះ តុលាការកំពូលត្រូវសំរេចដល់អង្គសេចក្តី ហើយតាមកំណត់ហេតុចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ១៩៩៣ លោក លាង ទ្រី ភូមិបាលស្រុក

ត្បូងឃ្មុំអះអាងថាមានពាក្យសុំកាន់កាប់ដីរបស់ឈ្មោះ ហេង ហុង មានទំហំដី២៥ម គុណ ៥០ម ប៉ុន្តែពាក្យសុំកាន់កាប់នេះពុំមានបញ្ជូលមកជាភស្តុតាងក្នុងសំណុំរឿងនេះទេ ដូច្នេះដើម្បីមានមូលដ្ឋានក្នុងការសំរេច តុលាការកំពូល គប្បីចាត់របៀបអោយការិយាល័យភូមិបាលស្រុកត្បូងឃ្មុំបញ្ជូនពាក្យសុំខាងលើមកតុលាការកំពូល ។

ហេតុដូច្នេះសំរេច

៙ ៚

១- ចាត់របៀបអោយភូមិបាលស្រុកត្បូងឃ្មុំ ចាត់បញ្ជូនឯកសារ និង ពាក្យសុំកាន់កាប់ដីរបស់ឈ្មោះ ហេង ហុង មកតុលាការកំពូល ក្នុងករណីចាំបាច់ តុលាការគប្បីធ្វើការស៊ើបអង្កេតបន្ថែម ។

២- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០២ ។